RGC

ROYAL GROUP

**PHNOM PENH SEZ**

# របាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២២

( គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ )

# ព័ត៌មាន ហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ ( ពាន់រៀល ) | ត្រីមាសទី១-២០២២ | ឆ្នាំ ២០២១ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ៤២៧.៣៦៦.០៥២ | ៤២៦.២៣៤.០០២ | ៣៨៤.០៦១.៦៣០ |
| បំណុលសរុប | ១៨៥.២០៣.៦៨៩ | ១៧៨.២៣១.០២៨ | ១៤១.០៧៥.៥៥៩ |
| មូលធនសរុប | ២៤២.១៦២.៣៦៣ | ២៤៨.០០២.៩៧៤ | ២៤២.៩៨៦.០៧១ |

| លទ្ធផលហិរញ្ញវត្ថុ ( ពាន់រៀល ) | ត្រីមាសទី១-២០២២ | ត្រីមាសទី១ ឆ្នាំ ២០២១ | ត្រីមាសទី១-២០២០ |
|---|---|---|---|
| ចំណូលសរុប | ១៨.០៥៦.៧៦៣ | ៧.១៤០.៥៩៤ | ១៥.៧៤៨.២១៨ |
| ចំណេញ/( ខាត )មុនបង់ពន្ធ | ( ២.៧០៩.៦៤៤ ) | ( ២.៩២៨.៤០៣ ) | ១.១៧០.៩១២ |
| ចំណេញ/( ខាត ) សុទ្ធក្រោយបង់ពន្ធ | ( ២.៧៥៧.០០៩ ) | ( ៣.៧២៧.០៤៨ ) | ៤៧៤.១៦១ |

| អនុបាតហិរញ្ញវត្ថុ | | ត្រីមាសទី១-២០២២ | ឆ្នាំ ២០២១ | ឆ្នាំ ២០២០ |
|---|---|---|---|---|
| អនុបាតសាធនភាព | | | | |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ២,៧៩ | ២,៩០ | ៥,៦១ |
| | អនុបាតចរន្តលឿន | ១,១៦ | ១,២៤ | ២,២៣ |
| | | ត្រីមាសទី១-២០២២ | ត្រីមាសទី១ ឆ្នាំ ២០២១ | ត្រីមាសទី១-២០២០ |
| អនុបាតចំណេញភាព | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម | ( ០,៦៥% ) | ( ០,៩៨% ) | ០,១២% |
| | ផលចំណេញក្នុងមួយឯកតាមូលធន | ( ១,១៤% ) | ( ១,៥៦% ) | ០,២០% |
| | គំលាតចំណេញដុល | ២៨,៨៣% | ៥៥,៦៤% | ៥១,១៨% |
| | គំលាតចំណេញភាព | ( ១៥,២៧% ) | ( ៥២,២០% ) | ៣,០១% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ( ៣៨,៤ ) | ( ៥១,៩ ) | ៦,៦ |
| អនុបាតលទ្ធភាពបង់ការប្រាក់ ( ថ្លៃហិរញ្ញវត្ថុ ) | | ( ១,២៦ ) | ( ០,៩៧ ) | ១,៧៩ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ ( ប្រសិនមាន ) ( ពាន់រៀល/ឯកតាមូលបត្រកម្មសិទ្ធិ ) | | - | - | - |

# លទ្ធផលហិរញ្ញវត្ថុរួមបញ្ចូលសម្រាប់រយៈពេល ៤ ត្រីមាសចុងក្រោយ




# រចនាសម្ព័នដើមទុន (ត្រឹមថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២២)



# Shareholding Structure (as of 31 March 2022)




**Remark:** Substantial Shareholders mean those who hold more than 1% of voting shares in the company.

# សមាសភាពក្រុមប្រឹក្សាភិបាល



**អ្នកឧកញ៉ា គិត ម៉េង**
ប្រធានក្រុមប្រឹក្សាភិបាល



**លោក Hiroshi Uematsu**
អភិបាលប្រតិបត្តិ



**លោក Kang Wei Geih**
អភិបាលឯករាជ្យ



**លោក Arthur Law Hian Tat**
អភិបាលឯករាជ្យ



**លោក Hiroshi Otsubo**
អភិបាលមិនប្រតិបត្តិ



**លោក Mark Hanna**
អភិបាលមិនប្រតិបត្តិ



**លោក Tanate Piriyothinkul**
អភិបាលមិនប្រតិបត្តិ



# អ្នកឧកញ៉ា គិត ម៉េង

ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០២២

ប្រធានក្រុមប្រឹក្សាភិបាល



អ្នកឧកញ៉ា គិត ម៉េង

## សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ជូនចំពោះម្ចាស់ភាគហ៊ុនជាទីគោរព

នៅក្នុងត្រីមាសទី១ ក្នុងឆ្នាំ ២០២១ ក្រុមហ៊ុនទទួលបានប្រាក់ចំណូលសរុប ១៨.០៥៦.៧៦៣ ពាន់រៀល ដែលមាន ការកើនឡើង ចំនួន ១៥២.៨៧% បើប្រៀបធៀបទៅនឹងចំនួនទឹកប្រាក់ ៧.១៤០.៥៩៤ ពាន់រៀល ក្នុងត្រីមាសទី១ នៅឆ្នាំ២០២១។ ជាលទ្ធផល ក្រុមហ៊ុនខាតសុទ្ធចំនួន ២.៧៥៧.០០៩ ពាន់រៀល បើប្រៀបធៀបនឹងការខាតសុទ្ធចំនួន ៣.៧២៧.០៤៨ ពាន់រៀល ក្នុងត្រីមាសដូចគ្នា ក្នុងឆ្នាំ ២០២១ ។ ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅតែបន្តរឹងមាំ នៅក្នុងថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២២ នេះ ដោយមានទ្រព្យសកម្មសរុបចំនួន ៤២៧.៣៦៦.០៥២ ពាន់រៀល ដែលរួមមានទ្រព្យសកម្មរយៈពេលវែងចំនួន ១៧០.៨៥៨.៧៦៣ ពាន់រៀល និងទ្រព្យសកម្មរយៈពេលខ្លីចំនួន ២៥៦.៥០៧.២៨៩ ពាន់រៀល។ មូលធនសរុបមានចំនួន ២៤២.១៦២.៣៦៣ ពាន់រៀល ដែលមានការថយចុះចំនួន ២,៣៦% បើប្រៀបធៀបទៅនឹងចំនួន ២៤៨.០០២.៩៧៤ ពាន់រៀល ឆ្នាំ២០២១។ ជាលទ្ធផល អនុបាតបំណុល មូលធនគឺ ០,៧៦នៅឆ្នាំ២០២២ ដែលធៀបនឹងចំនួនអនុបាតបំណុល មូលធន ០,៧២នៅឆ្នាំ២០២១ ។

# មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ក្រាហ្វិកអំពី
ព័ត៌មានហិរញ្ញវត្ថុសង្ខេប
សមាសភាពក្រុមប្រឹក្សាភិបាល
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល
សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ

**ផ្នែកទី ១ : ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលបោះផ្សាយ**
១- ព័ត៌មានទូទៅអំពីបុគ្គលបោះផ្សាយ
២- លក្ខណៈនៃរធុរកិច្ច
៣- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

**ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច**
១- លទ្ធផលប្រតិបត្តិការធុរកិច្ច
៣- រចនាសម្ព័ន្ធចំណូល

**ផ្នែកទី៣ : របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ**

**ផ្នែកទី ៤ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង**
១- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ
២- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ
៣- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល
៤- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ( Commodity )
៥- ផលប៉ះពាល់នៃអតិផរណា
៦- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាល

**ផ្នែកទី ៥ ព័ត៌មានផ្សេងទៀតដើម្បីការពារវិនិយោគិន**

**ហត្ថលេខារបស់អភិបាលរបស់បុគ្គលបោះផ្សាយ**

# ផ្នែកទី ១ : ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលបោះផ្សាយ

## ១.១. ព័ត៌មានទូទៅអំពីបុគ្គលបោះផ្សាយ

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ: ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី
ជាអក្សរឡាតាំង: PHNOM PENH SEZ PLC.
អក្សរកូដ: KH1000050000
អាសយដ្ឋាន: តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ផ្លូវជាតិលេខ ៤ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
លេខទូរស័ព្ទ: (+៨៥៥) ២៣ ៧២៩ ៧៩៨
លេខទូរសារ: (+៨៥៥) ២៣ ៧២៩ ៧៩៩
គេហទំព័រ: www.ppsez.com
អ៊ីម៉ែល: info@ppsez.com
លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម: Inv. ១០៧៦ KH/២០០៦
កាលបរិច្ឆេទ: ១០ ឧសភា ២០០៦
លេខអាជ្ញាបណ្ណអាជីវកម្ម: ៣៣ អនក្រ.បក (អនុក្រឹត្យ)
ចេញដោយ: រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា កាលបរិច្ឆេទ: ១៩ មេសា ២០០៦
សេចក្ដីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន លេខ: ០២៦/១៦ គ.ម.ក./ស.ស.រ
កាលបរិច្ឆេទ: ២៣ មីនា ២០១៦
បុគ្គលតំណាងបុគ្គលបោះផ្សាយ: អ្នកឧកញ៉ា គិត ម៉េង

តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ បានផ្លាស់ប្ដូរឈ្មោះទៅជា តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ នៅថ្ងៃទី១៦ មីនា ឆ្នាំ២០២២

តំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត ភីភី បានផ្លាស់ប្ដូរឈ្មោះទៅជា តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ប៉ោយប៉ែត នៅថ្ងៃទី១៦ មីនា ឆ្នាំ២០២២

## ១.២. ដំណើរការធុរកិច្ចសង្ខេប

ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី គឺជាអ្នកអភិវឌ្ឍ និងជាប្រតិបត្តិករនៃ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ និងតំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ប៉ោយប៉ែត ដែលជាប្រតិបត្តិករ តំបន់សេដ្ឋកិច្ចដែលឈរមុខគេក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសផ្សេងទៀត នៅព្រះរាជាណាចក្រកម្ពុជា ។ នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ក្រុមហ៊ុនទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា ដើម្បីក្លាយខ្លួនជា អ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសដែលអាចធ្វើប្រតិបត្តិការអាជីវកម្មច្រើនប្រភេទ ហើយបច្ចុប្បន្ននេះ យើងខ្ញុំជាតំបន់សេដ្ឋកិច្ចពិសេស ដែលកំពុងធ្វើប្រតិបត្តិការនៅជិតទីប្រជុំជននៃរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ងារជាតំបន់សេដ្ឋកិច្ចពិសេស បានផ្តល់នូវការលើកទឹកចិត្ត និងអត្ថប្រយោជន៍ជាច្រើនពីសំណាក់រាជរដ្ឋាភិបាលដល់អ្នកអភិវឌ្ឍ ប្រតិបត្តិករ និងវិនិយោគិនតំបន់ ដែលរួមមានការលើកលែងពន្ធគយ ពន្ធលើប្រាក់ចំណូល និងពន្ធដទៃទៀតដែលជាលទ្ធផលធ្វើឲ្យមានការកាត់បន្ថយលើការចំណាយសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈប្រើប្រាស់វត្ថុធាតុដើម និងធនធានដទៃទៀត ដែលធ្វើឲ្យមានការបង្កើនការប្រកួតប្រជែងសម្រាប់ការនាំចេញ និងអត្ថប្រយោជន៍ជំនួញអន្តរជាតិ។

ក្រុមហ៊ុនយើងខ្ញុំ មានធុរកិច្ចចម្បងលើការធ្វើប្រតិបត្តិការ និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដែលមានកម្មវត្ថុអាជីវកម្មចម្បងក្នុងការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់ និង/ឬ ជួល។ បន្ថែមពីលើនេះ ក្នុងនាមជាប្រតិបត្តិករ ក្រុមហ៊ុនយើងបានចូលរួមផ្គត់ផ្គង់សេវាកម្មចាំបាច់ពាក់ព័ន្ធ និងបរិក្ខារចាំបាច់នានា នៅក្នុងបរិវេណ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ដែលរួមមានការផ្គត់ផ្គង់ និងចែកចាយទឹកស្អាត សេវាជួលការថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មផ្តល់ប្រឹក្សាយោបល់ និងជំនួយកិច្ចការរដ្ឋបាល ប្រព្រឹត្តិកម្មទឹកសំអុយ និងសេវាកម្មដទៃទៀត។ បច្ចុប្បន្ន យើងកំពុងធ្វើប្រតិបត្តិការ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ដែលមានទីតាំងស្ថិតនៅលើផ្លូវជាតិលេខ៤ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

បច្ចុប្បន្ន តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ កំពុងប្រតិបត្តិការនៅជិតទីប្រជុំជននៃរាជធានីភ្នំពេញ។ គិតត្រឹមកាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ជាតំបន់សេដ្ឋកិច្ចពិសេសមួយ ក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសដប់ប្រាំពីរ (១៧) ដែលកំពុងមានប្រតិបត្តិការ (ក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសទាំងសាមសិបបួន (៣៤) ដែលទទួលបានការអនុញ្ញាត) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ បើគិតតាមវិនិយោគិនតំបន់ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ មានវិនិយោគិនតំបន់ច្រើនជាងគេនៅកម្ពុជា។ លើសពីនេះទៀត តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ជាតំបន់សេដ្ឋកិច្ចពិសេសធំមួយ ក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសដែលមានផ្ទៃដីធំជាងគេនៅ កម្ពុជា បើគិតតាមទំហំនៃផ្ទៃដីរបស់ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ប្រមាណ ៣៥៧,៣២ ហិកតា។

គិតត្រឹម ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ក្រុមហ៊ុនរបស់យើងមានបុគ្គលិកចំនួន កៅសិបប្រាំមួយ (៩៦)នាក់។ សម្ព័ន្ធក្រុមហ៊ុនយើងក៏មានផ្តល់នូវសេវាសន្តិសុខ ផលិត និងចែកចាយថាមពលអគ្គិសនី និងសេវាផែស្ងួត តាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុនជាសម្ព័ន្ធភាពរបស់យើង ជូនវិនិយោគិនតំបន់ និងអ្នកជួលដទៃទៀតក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ។ នៅក្នុងត្រីមាសនេះ យើងបានបង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធថ្មីចំនួន ៣ រួមមាន: ១) ក្រុមហ៊ុន PPSEZ II Co.,Ltd សម្រាប់ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសថ្មី ២) Sahas Properties Co.,Ltd ជាក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យរបស់យើងនិង ៣) ក្រុមហ៊ុនGomi Recycle (Phnom Penh) Co. , Ltd. ដែលយើងសហការជាដៃគូជាមួយក្រុមហ៊ុនជប៉ុនសម្រាប់អាជីវកម្មគ្រប់គ្រងសំណល់រឹង។

គិតត្រឹម ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២រចនាសម្ព័ន្ធសាជីវកម្មរបស់សម្ព័ន្ធក្រុមហ៊ុនរបស់យើងមាន ដូចខាង ក្រោម៖

ROYAL GROUP
PHNOM PENH SEZ




| ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | ភាគរយនៃការកាន់កាប់ភាគហ៊ុន | ផ្នែកអាជីវកម្ម | កាលបរិច្ឆេទចុះបញ្ជី | អាសយដ្ឋានអាជីវកម្ម |
|---|---|---|---|---|---|
| សហ័ស ភីភីអេសអ៊ីហ្សិត | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ១០០% | សេវាសន្តិសុខឯកជន | ០៦ វិច្ឆិកា ២០១៣ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រាជធានីភ្នំពេញ |
| ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ១០០% | ពាណិជ្ជកម្ម និងជំនួញ | ៣១ ធ្នូ ២០១៤ | ខេត្តបន្ទាយមានជ័យ |
| សហ័ស អ៊ី & ស៊ី | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ៦០% | វិស្វកម្ម និងសំណង់ | ២៤ មករា ២០១៧ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រាជធានីភ្នំពេញ |
| សហ័សប្រជីធីស៍ ឯ.ក | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ១០០% | អភិវឌ្ឍផ្នែកអចលនទ្រព្យ | ១៥ វិច្ឆិកា ២០១៨ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រាជធានីភ្នំពេញ |
| ភ្នំពេញ ភីភីអេសអ៊ីហ្សិត ២ ឯ.ក | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ១០០% | អភិវឌ្ឍ និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស | ៣១ តុលា ២០១៨ | រាជធានីភ្នំពេញ |
| ខ្ចលបេន ភីភីអេសអ៊ីហ្សិត | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ៥១% | រោងចក្រផលិតថាមពលអគ្គិសនី | ១៥ វិច្ឆិកា ២០១៨ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រាជធានីភ្នំពេញ |
| បុក សេង ភីភីអេសអ៊ីហ្សិត | ក្រុមហ៊ុនជាសម្ព័ន្ធភាព | ៤០% | ផែស្ងួត | ២២ មករា ២០០៨ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រាជធានីភ្នំពេញ |
| សហ័ស អ៊ែដវ៉ាយស៊ីរី & ខន់សាល់ធីង | ក្រុមហ៊ុនជាសម្ព័ន្ធភាព | ៣៩% | ភ្នាក់ងារសេវាកម្មផ្នែកពន្ធដារ | ១៤ កុម្ភៈ ២០០១៧ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រាជធានីភ្នំពេញ |
| ហ្គោមី រីសាយឃល (ភ្នំពេញ) ឯ.ក | ក្រុមហ៊ុនជាសម្ព័ន្ធភាព | ២៥.៥% | ការគ្រប់គ្រងកាកសំណល់រឹង | ១៣ វិច្ឆិកា ២០១៨ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រាជធានីភ្នំពេញ |
| ប៊ីគ្រីម ផៅវើ (ប៉ោយប៉ែត) ឯ.ក | ក្រុមហ៊ុនជាសម្ព័ន្ធភាព | ៤៥% | ប្រព័ន្ធបញ្ជូននិងចែកចាយថាមពលអគ្គិសនី | ២០ វិច្ឆិកា ២០១៣ | ខេត្តបន្ទាយមានជ័យ |

យើងចាប់ផ្ដើមប្រតិបត្តិការរបស់យើងក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ក្នុងឆ្នាំ២០០៧ ជាមួយនឹងការសាងសង់ដំណាក់កាល១ នៃ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ហើយមកដល់ខែសីហា ឆ្នាំ២០០៨ យើងទទួលបានវិនិយោគិនតំបន់ដំបូងគេបង្អស់ ដែលចាប់ផ្ដើមធ្វើប្រតិបត្តិការក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ។ ច្រើនឆ្នាំកន្លងមកនេះ ការកើនឡើងនៃការចាប់អារម្មណ៍ពីសំណាក់វិនិយោគិនជាតិ និងអន្តរជាតិ ក្នុងការធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួនក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ បានធ្វើឲ្យ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ មានការរីកចម្រើនយ៉ាងឆាប់រហ័ស។ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ មានវិនិយោគិនមកពី១ ជាតិសាសន៍ចំនួន៩២ ដែលវិនិយោគិនភាគច្រើនមកពីប្រទេសជប៉ុន ម៉ាឡេស៊ី តៃវ៉ាន់ ចិន សហរដ្ឋអាមេរិក និងកូរ៉េដែលវិនិយោគលើឧស្សាហកម្មផ្សេងៗគ្នា ដូចជា គ្រឿងបន្លាស់យានយន្ត កាត់ដេរ អាហារនិងភេសជ្ជៈ ផលិតផល ប្លាស្ទិច ផលិតផលអេឡិចត្រូនិច និងគ្រឿងអលង្ការ។បច្ចុប្បន្ន យើងកំពុងប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ទីតាំងរបស់ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ មានបង្ហាញដូចខាងក្រោម៖




តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញមានទីតាំងយុទ្ធសាស្ត្រ ដែលតភ្ជាប់ទៅនឹងបណ្ដាញផ្លូវដែក និងបណ្ដាញផ្លូវថ្នល់។
តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ មានទីតាំងស្ថិតនៅចម្ងាយប្រមាណជា១៨ គីឡូម៉ែត្រ ពីចំណុចកណ្ដាលនៃរាជធានីភ្នំពេញ ដែលងាយស្រួលក្នុងការធ្វើដំណើរទៅកាន់កំពង់ផែស្វយ័តភ្នំពេញ កំពង់ផែទន្លេអន្តជាតិនៅរាជធានីភ្នំពេញ និងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិធំជាងគេនៅកម្ពុជា។ ជាងនេះទៅទៀត តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ៤ ដែលជាផ្លូវគមនាគមន៍ចម្បង និងងាយស្រួលក្នុងការធ្វើដំណើរទៅកាន់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលជាកំពង់ផែអន្តរជាតិ និងពាណិជ្ជកម្មសមុទ្រទឹកជ្រៅតែមួយគត់របស់កម្ពុជា។
បន្ថែមលើទីតាំងយុទ្ធសាស្ត្ររបស់ខ្លួន តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ជួយសម្រួល និងទាក់ទាញវិនិយោគិនរបស់ខ្លួន តាមរយៈលក្ខណៈពិសេសដូចខាងក្រោម៖
រោងចក្រផលិតថាមពលអគ្គិសនីឯកជន ធ្វើការផ្គត់ផ្គង់ថាមពលអគ្គិសនី នៅពេលដែលមានកង្វះខាតថាមពលអគ្គិសនីពីរោងចក្រផ្គត់ផ្គង់អគ្គិសនីជាតិ ដែលដំណើរការដោយក្រុមហ៊ុន ខូលបេន ភីភីអេសអ៊ីហ្សេត ដែលជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនជាសម្ព័ន្ធភាពទាំងអស់របស់ក្រុមហ៊ុនយើង។

**I.**ប្រព័ន្ធផ្គត់ផ្គង់ទឹកឯកជន ដែលមានស្ថានីយ៍បន្សុទ្ធទឹក និងប្រព្រឹត្តិកម្មទឹកសំអុយ។

**II.**ផែស្ងួតក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុបភ្នំពេញផ្ដល់សេវាលើកដាក់ និងសេវាផ្ទុកទំនិញដែលអាចទុកចិត្តបាន និងឆាប់រហ័សដើម្បីសម្រួលដល់ការនាំចេញនាំចូល និងដល់តម្រូវការដឹកជញ្ជូននានា ដែលដំណើរការដោយក្រុមហ៊ុន បុកសេង ភីភីអេសអ៊ីហ្សេតដែលជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនជាសម្ព័ន្ធភាពទាំងអស់របស់ក្រុមហ៊ុនយើង។

**III.**បណ្ដាញទូរគមនាគមន៍ខ្វាត់ខ្វែងនិងធំទូលាយដែលអាចតភ្ជាប់ជាមួយអ្នកផ្ដល់សេវាកម្ម អ៊ីនធឺណេតចំនួន១២ផ្សេងគ្នានិងអ្នកផ្ដល់សេវាកម្មទូរស័ព្ទខុសគ្នាចំនួន៤។

**IV.**ប្រព័ន្ធទប់ស្កាត់ទឹកជំនន់បំពាក់ដោយប្រព័ន្ធបង្ហូរទឹកទំនើប ដែលធានាដល់ប្រតិបត្តិការរបស់វិនិយោគិនតំបន់ឲ្យមានភាពរលូន និងមានសុវត្ថិភាពខ្ពស់។

**V.** សេវាសន្តិសុខផ្ដល់ដោយក្រុមហ៊ុនសហ័សភីភីអេសអ៊ីហ្សិតជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលកាន់កាប់ទាំងស្រុងដោយក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិតភីអិលស៊ីដើម្បីត្រួតពិនិត្យនិងរក្សាសុវត្ថិភាពក្នុងតំបន់។ និង

**VI.** "សេវាច្រកចេញចូលតែមួយ" ដែលមាននៅក្នុងតំបន់ស្រាប់ ដែលសហការជាមួយភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធនានា ដូចជាភ្នាក់ងាររបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា នាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា កាំកុងត្រូល ក្រសួងពាណិជ្ជកម្ម និងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈដើម្បីសម្រួលដល់ការបង់ពន្ធគយ ការចុះបញ្ជីពាណិជ្ជកម្មនិងការគោរពតាមច្បាប់ដល់វិនិយោគិនតំបន់របស់ខ្លួន។

ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដ៏ទំនើប តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ បានទាក់ទាញវិនិយោគិនជាច្រើនឲ្យមកបង្កើតប្រតិបត្តិការរបស់ពួកគេក្នុងតំបន់។ ក្រុមហ៊ុនរបស់ពួកយើងមានសេវាកម្មដូចខាងក្រោមនេះ៖

## ១.២.១. ការលក់ដី

សម្រាប់រយៈពេលដប់ ( ១០ ) ឆ្នាំសារពើពន្ធចាប់ពី ឆ្នាំ២០១២ រហូតដល់ឆ្នាំ២០២១ ចំណូលបានពីការលក់ដីក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ  គឺជាផ្នែកសំខាន់នៃប្រាក់ចំណូលដុលរបស់សម្ព័ន្ធក្រុមហ៊ុនយើង។ ប្រាក់ចំណូលដុលដែលបានពីការលក់ដីអាស្រ័យទៅលើចំនួនឡូតិ៍ និងទំហំនៃឡូតិ៍នីមួយៗដែលត្រូវបានលក់។

តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ មានទីតាំងប្រហែលជាដប់ប្រាំបី ( ១៨ ) គីឡូម៉ែត្រពីចំណុចកណ្ដាលនៃ រាជធានីភ្នំពេញ ហើយស្ថិតនៅជាប់ជាមួយផ្លូវជាតិលេខ៤។ ក្នុងនាមជាវិនិយោគិនតំបន់សេដ្ឋកិច្ចពិសេស វិនិយោគិនតំបន់អាចស្នើសុំ និងទទួលបានការលើកទឹកចិត្តពីរាជរដ្ឋាភិបាល និងទទួលបាននូវអត្ថប្រយោជន៍ ដែលបានមកពីការកាត់បន្ថយចំណាយ លើហេដ្ឋារចនាសម្ព័ន្ធ នៅពេលវិនិយោគិនតំបន់បង្កើតរោងចក្ររបស់ខ្លួនក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ។

យោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរប៉ុណ្ណោះ ដែលមានសិទ្ធិកម្មសិទ្ធិលើដីក្នុងព្រះរាជាណាចក្រកម្ពុជា ដូចនេះ ការលក់ដីដែលធ្វើឡើងក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ គឺតាមការលក់ផ្ដាច់ ឬការជួលរយៈពេលវែង។ ប្រតិបត្តិការលក់ដីធ្វើឡើងសម្រាប់អ្នកទិញក្នុងស្រុក តាមរយៈកិច្ចព្រមព្រៀងទិញលក់ ដែលក្នុងនោះ បណ្ណសម្គាល់កម្មសិទ្ធិដីនៃដីឡូតិ៍ដែលត្រូវលក់នោះ នឹងត្រូវផ្ទេរទៅឲ្យអ្នកទិញនៅពេលកិច្ចព្រមព្រៀងនោះត្រូវបានបញ្ចប់។ ម្យ៉ាងវិញទៀត ការជួលរយៈពេលវែងដែលអាចជួលឲ្យអ្នកជួលក្នុងស្រុក ឬបរទេស ត្រូវបានអនុវត្តតាមរយៈកិច្ចព្រមព្រៀងជួលរយៈពេលហាសិប ( ៥០ )ឆ្នាំ ដែលមិនអាចប្ដូរជាប្រាក់វិញបាន ដោយភ្ជាប់មកជាមួយនឹងជម្រើសក្នុងការពន្យាពេលបានរយៈពេលហាសិប ( ៥០ ) ឆ្នាំទៀត តាមខសន្យា និងលក្ខខណ្ឌដែល ដែលអាចបន្តជាថ្មីដោយអ្នកជួល។

### សម្រាប់រយៈពេលដប់ ( ១០ ) ឆ្នាំសារពើពន្ធចាប់ពី ឆ្នាំ២០១២ រហូតដល់ឆ្នាំ២០២១ចំនួនប្រតិបត្តិការលក់ដីរបស់ក្រុមហ៊ុនក្នុង តំបន់សេដ្ឋកិច្ចពិសេសរ៉ូយ៉ាល់គ្រុប ភ្នំពេញ ដែលត្រូវបានធ្វើឡើងតាមរយៈការទិញ និងការជួលរយៈពេលវែងមានដូចខាងក្រោម:

| ពិពណ៌នា | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២២ | ២០២១ | ២០២០ | ២០១៩ | ២០១៨ | ២០១៧ | ២០១៦ | ២០១៥ | ២០១៤ | ២០១៣ | ២០១២ |
| ការលក់ផ្ដាច់ | ០ | ០ | ០ | ០ | ០ | ១ | ០ | ០ | ០ | ១ | ៣ |
| ការជួលរយៈពេលវែង | ០ | ០ | ៣ | ៨ | ៧ | ៩ | ៩ | ៨ | ៨ | ១៤ | ១១ |
| ប្រតិបត្តិការលក់ដីសរុប | ០ | ០ | ៣ | ៨ | ៧ | ១០ | ៩ | ៨ | ៨ | ១៥ | ១៤ |

### ដោយគិតត្រឹម ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុបភ្នំពេញមានដីសរុបទំហំប្រមាណ ៣៥៧,៣២ ហិកតា ដែលនឹងត្រូវអភិវឌ្ឍជាបី ( ០៣ ) ដំណាក់កាលដូចខាងក្រោម៖

I.ដំណាក់កាល១ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារសំខាន់ៗបានបញ្ចប់ក្នុងឆ្នាំ២០០៩។ វាមានទំហំសរុបប្រមាណ ១៣៧,៩៤ ហិកតា ដែលក្នុងនោះផ្ទៃដីប្រមាណ ៨៦,៧១ ហិកតា ត្រូវបានអភិវឌ្ឍជាទីតាំងដីឡូតិ៍សម្រាប់រោងចក្រចំនួនហុកសិបមួយ ( ៦១ ) ដែលឡូតិ៍នីមួយៗមានទំហំចាប់ពី ០,១៩ ហិកតា ដល់ ១០,៥៧ ហិកតា។ ដំណាក់
កាល១ ក៏រួមបញ្ចូលនូវដីប្រមាណ ២៤,៤៦ ហិកតា ដែលត្រូវបានរៀបចំសម្រាប់ការអភិវឌ្ឍ ពាណិជ្ជកម្មដែលអាចបង្កើតជាទីតាំងផ្សេងៗដូចជា ហាង ភោជនីយដ្ឋាន ធនាគារ។ បន្ថែមពីនេះ ផ្ទៃដីប្រហែល ១,៥៣ ហិកតា ត្រូវបានរៀបចំធ្វើជាកន្លែងស្នាក់នៅឲ្យកម្មករ តំបន់នៅសល់ត្រូវបានរៀបចំសម្រាប់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម ដែលរួមមានទីស្នាក់ការកណ្ដាលរបស់យើង។

II.ដំណាក់កាល២ មានទំហំប្រមាណ ១៦១,៥៩ ហិកតា ដែលត្រូវបានបែងចែកជាពីរ ( ០២ ) ផ្នែកផ្សេងទៀត គឺដំណាក់កាល២-១ និង ដំណាក់កាល២-២។
ចំពោះដំណាក់កាល២-១ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារបានបញ្ចប់ក្នុងឆ្នាំ២០១៤។ ដំណាក់កាល២-១ គ្របដណ្ដប់លើតំបន់ដែលមានទំហំប្រមាណ ៨៧,៨៥ ហិកតា ដែលក្នុងនោះ ៥៩,៨៥ ហិកតា ត្រូវបានអភិវឌ្ឍដើម្បីបង្កើតជាទីតាំងឡូតិ៍រោងចក្រចំនួនម្ភៃប្រាំបី ( ២៨ ) ដែលឡូតិ៍នីមួយៗមានទំហំចាប់ពី ០,៥០ ហិកតា ដល់ ១០ ហិកតា ហើយផ្ទៃដីប្រហែល ២,៨២ ហិកតា ត្រូវបានធ្វើជាកន្លែងស្នាក់នៅឲ្យកម្មករ នឹងដីនៅសល់ត្រូវបានប្រើសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ។ មកដល់បច្ចុប្បន្ន ដំណាក់កាល២-២ កំពុងអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារសំខាន់ៗ ដែលរំពឹងថានឹងបញ្ចប់នៅដើមឆ្នាំ២០១៦។

ដំណាក់កាល២-២ គ្រប់ដណ្ដប់លើដីដែលមានទំហំប្រមាណ ៧៣,៧៤ ហិកតា ដែលក្នុងនោះ ៥៧,៨២ ហិកតា ត្រូវបានអភិវឌ្ឍដើម្បីបង្កើតជាទីតាំងឡូតិ៍រោងចក្រចំនួនសាមសិបមួយ ( ៣១ ) ដែលដីឡូតិ៍នីមួយៗមានទំហំចាប់ពី ០,៦៤ ហិកតា ដល់ ៩,២៨ ហិកតា តំបន់នៅសល់ត្រូវបានប្រើសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងពាណិជ្ជកម្ម។ និង

III. ដំណាក់កាល៣ យើងមានដីទំហំប្រមាណ ៥៧,៧៩ ហិកតា ។ នៅក្នុងឆ្នាំនេះ យើងបានឈានដល់កិច្ចព្រមព្រៀងលក់ដីទំហំ ៤១,៣ ហិកតា ទៅអោយក្រុមហ៊ុន Shenzhou International Group ដែលជាក្រុមហ៊ុនផលិតសម្លៀកបំពាក់ដែលមានគុណភាពខ្ពស់បំផុតនៅក្នុងប្រទេសចិន។ ប្រតិបត្តិការនេះត្រូវបានចាត់ទុកថាជាប្រតិបត្តិការលក់ដីធ្លីធំបំផុតដែលមិនធ្លាប់មានពីមុនសម្រាប់ក្រុមហ៊ុន។

ចាប់ឆ្នាំ២០១០ ក្រុមហ៊ុនយើងបានទទួលវិញ្ញាបនបត្របញ្ជាក់បទដ្ឋានអន្តរជាតិ ISO 9001 សម្រាប់ការប្ដេជ្ញាក្នុងការគ្រប់គ្រងយ៉ាងមានគុណភាព និង ISO 14001 សម្រាប់ការប្ដេជ្ញាក្នុងការត្រួតពិនិត្យបរិស្ថានរបស់ខ្លួន។




## ១.២.២. សេវាកម្មដែលផ្តល់ជូន

ស្របជាមួយនឹងការអភិវឌ្ឍនៃការលក់ដីក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ក្រុមហ៊ុនយើងផ្តល់ឲ្យអ្នកជួលក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ នូវសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ក្នុងការសម្រួលដល់ប្រតិបត្តិការរបស់ពួកគេដែលរួមមាន៖



## បរិក្ខារ

ក្រុមហ៊ុនរបស់យើង ផ្តល់ឲ្យអ្នកជួលនៅក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ នូវការផ្គត់ផ្គង់ទឹកដែលមានស្ថេរភាព និងឯករាជ្យ។ យើងផ្គត់ផ្គង់ទឹកតាមរយៈការដំឡើងស្ថានីយ៍ចម្រោះទឹក ដែលមានសមត្ថភាពផលិតទឹកស្អាតចំនួន ១៤.៩០០ ម៣ ក្នុងមួយថ្ងៃ។ រោងចក្រចម្រោះទឹកមានទីតាំងស្ថិតនៅក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ដោយវាប្រមូលទឹកពីស្ទឹងព្រែកត្នោតដែលមានទីតាំងជាប់នឹង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ។ លើសពីនេះ ទឹកមួយចំនួនទៀតក៏មានប្រភពពីទឹកភ្លៀង ដែលយើងប្រមូលដោយប្រើប្រាស់នូវត្រពាំងស្តុកទឹកភ្លៀង ដែលមានសមត្ថភាពស្តុកចំនួន ២៥.០០០ ម៣។ ត្រពាំងស្តុកទឹកភ្លៀង ត្រូវបានប្រើជាប្រព័ន្ធបម្រុងសម្រាប់ផ្គត់ផ្គង់ទឹកបណ្តោះអាសន្ន ក្នុងករណីដែលការផ្គត់ផ្គង់ទឹកពីទឹកស្ទឹងមានភាពរអាក់រអួល។ មុនពេលផ្គត់ផ្គង់ទឹកទៅអ្នកជួលក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ វិស្វករដែលមានបទពិសោធន៍ក្នុងការចម្រោះទឹក បានធ្វើតេស្តគុណភាពរបស់ទឹកដោយប្រើឧបករណ៍ទំនើប និងមានប្រសិទ្ធភាព នៅក្នុងមន្ទីរពិសោធន៍របស់ស្ថានីយ៍ ដើម្បីធានាគុណភាពទឹកស្របតាមស្តង់ដារឧស្សាហកម្ម។ ក្រុមហ៊ុនរបស់យើងបានដំឡើងអាងស្តុកទឹកកំពស់ខ្ពស់ និងអាងទឹកសរុបចំនួនប្រាំ (០៥) សម្រាប់ស្តុកទឹក និងបង្កើនសម្ពាធទឹកសម្រាប់ការប្រើប្រាស់របស់អ្នកជួល។ យើងបានចូលរួមក្នុងប្រតិបត្តិការរោងចក្រផលិតអគ្គិសនីក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ តាមរយៈក្រុមហ៊ុនជាសម្ព័ន្ធរបស់យើង គឺក្រុមហ៊ុន ខូលបេន ភីភីអេសអឺហ្សេត ដែលផ្គត់ផ្គង់អគ្គិសនីសម្រាប់អ្នកជួល និងរាល់អគារនៅក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ សម្រាប់ប្រើប្រាស់ក្នុងករណីដែលមានការខ្វះខាតថាមពល ដែលផ្គត់ផ្គង់ដោយអគ្គិសនីជាតិ។ រោងចក្រផលិតអគ្គិសនីនេះ ត្រូវបានសង់នៅលើផ្ទៃដីដែលមានទំហំប្រមាណ ៥,០៤ ហិកតា និងមានសមត្ថភាពផលិតអគ្គិសនីសរុប១៣ មេហ្គាវ៉ាត តាមរយៈម៉ាស៊ីនភ្លើងធុនធំប្រើប្រេងឥន្ធនៈចំនួនបី ។



## ការថែទាំហេដ្ឋារចនាសម្ព័ន្ធ

ដើម្បីផ្គត់ផ្គង់ចំណាយក្នុងការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងប្រតិបត្តិការទូទៅរបស់ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ក្នុងទីធ្លាសាធារណៈ ដូចជាផ្លូវថ្នល់ អគ្គិសនីសម្រាប់អំពូលតាមផ្លូវ និងចំណាយថែទាំបរិក្ខារហេដ្ឋារចនាសម្ព័ន្ធក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ក្រុមហ៊ុនរបស់យើងប្រមូលថ្លៃថែទាំហេដ្ឋារចនាសម្ព័ន្ធពីអ្នកកាន់កាប់ក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ។ ថ្លៃថែទាំហេដ្ឋារចនាសម្ព័ន្ធនេះ ត្រូវបានប្រមូលផ្អែកលើទំហំដីរបស់អ្នកកាន់កាប់ ដែលត្រូវគុណដោយអត្រាកំណត់ទុកមុននៃថ្លៃថែទាំ។

## សេវាផ្តល់ប្រឹក្សា និងជំនួយរដ្ឋបាល

ដើម្បីជាមជ្ឈមណ្ឌលច្រកចេញចូលតែមួយ សម្រាប់វិនិយោគិនតំបន់របស់យើង ក្រុមហ៊ុនរបស់យើង ផ្តល់ប្រឹក្សា និងសេវាកម្មជំនួយរដ្ឋបាល។ ការផ្តល់ឲ្យនូវការប្រឹក្សា និងជំនួយខាងរដ្ឋបាលនេះមានគោលបំណងក្នុងការសម្រួលសកម្មភាពចុះបញ្ជីរបស់វិនិយោគិនតំបន់ក្នុងព្រះរាជាណាចក្រកម្ពុជា។

សេវាកម្មជំនួយរដ្ឋបាលទាំងនេះរួមមានការចុះបញ្ជីប្រតិបត្តិការអាជីវកម្មរបស់វិនិយោគិនតំបន់ជាមួយនឹងអាជ្ញាធរផ្សេងៗក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានដូចខាងក្រោម៖

- ការចុះបញ្ជីគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់
- ការដាក់ពាក្យសុំការលើកទឹកចិត្តផ្នែកពន្ធដារ
- ការរៀបចំបញ្ជីគោលសម្រាប់ការផលិត
- វិញ្ញាបនបត្រ និងការប្រកាសបើករោងចក្រ
- ការចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- វិញ្ញាបនបត្រប្រព័ន្ធអនុគ្រោះទូទៅ ( សម្រាប់វិនិយោគិនតំបន់ដែលត្រូវនាំទំនិញចេញ ) សម្រាប់ការបង់ពន្ធអាករ។

## ប្រព្រឹត្តិកម្មទឹកសំអុយ

យើងមានផ្តល់សេវាប្រព្រឹត្តិកម្មទឹកសម្រាប់ទឹកសំណល់ ដែលត្រូវបានបញ្ចេញចោលដោយអ្នកកាន់កាប់តំបន់ ដោយប្រើប្រាស់ប្រព័ន្ធបង្ហូរទឹកការពារច្រេះ ដែលត្រូវបានដំឡើងនៅក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ។ ស្ថានីយ៍ប្រព្រឹត្តិកម្មទឹកសំអុយ ប្រើប្រាស់ប្រព័ន្ធ Aerated Lagoon ដែលប្រើប្រាស់ Aeration Ponds ដែលមាន Aerators Settling Ponds និង Polishing Pond ដើម្បីច្រោះសារជាតុពុលក្នុងទឹកសំណល់មុនពេលបញ្ចេញចោលទៅក្រៅតំបន់ ឬប្រើប្រាស់ឡើងវិញក្នុងគោលបំណងស្រោចស្រពក្នុងបរិវេណតំបន់។ រូបភាពខាងក្រោមបង្ហាញពីការច្រោះទឹក និងបរិក្ខារប្រព្រឹត្តិកម្មទឹកសំអុយ នៅក្នុង PPSEZ៖





## ១.២.៣. ប្រាក់ចំណូលបានពីការជួល

យើងផ្តល់សេវាកម្មជួលអគាររួមមាន រោងចក្រ និវេសនដ្ឋាន ឃ្លាំង និងហាងក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ។ សេវាកម្មជួលទាំងនេះ ភាគច្រើនគឺជាការជួលរយៈពេលខ្លី។ ជាទូទៅរយៈពេលជួលមានចាប់ពីបី ដល់ប្រាំ ឆ្នាំ ជាមួយនឹងជម្រើសក្នុងការបន្តបីដល់ប្រាំឆ្នាំទៀត។

## ១.២.៤. អាជីវកម្មសំណង់

តាំងពីឆ្នាំ ២០១៧ យើងបានបង្កើតក្រុមហ៊ុន Sahas E&C Co,Ltd ដើម្បីពង្រីកអាជីវកម្មថ្មីក្នុងវិស័យវិស្វកម្មនិងសំណង់។ ក្រុមហ៊ុននេះចាប់ផ្តើមការងារសំណង់នៅក្នុងសម្ព័ន្ធក្រុមហ៊ុន ហើយក្រោយមកចាប់ផ្តើមទទួលយកកិច្ចព្រមព្រៀងពីអតិថិជនផ្សេងទៀត។
បច្ចុប្បន្ននេះយើងកំពុងអភិវឌ្ឍរោងចក្រជួល ដែលត្រូវបានផ្តល់ថវិកាដោយវិទ្យាស្ថានហិរញ្ញវត្ថុឈានមុខគេពីប្រទេសថៃ។ ប្រភេទនៃរោងចក្រជួលនេះបង្កើតឡើងដើម្បីតម្រូវការរបស់អតិថិជនក្នុងការជួលរយៈពេលជួលវែង។

## ១.២.៥. ស្ថានភាពទីផ្សារ

ទស្សនវិស័យទៅថ្ងៃអនាគតសម្រាប់តំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសកម្ពុជា ត្រូវបានព្យាករណ៍ថានឹងនៅមានភាពវិជ្ជមាន ស្របជាមួយនឹងការប្រមើលឃើញនូវកំណើនសេដ្ឋកិច្ចយ៉ាងខ្លាំងក្នុងប្រទេសកម្ពុជា។ ប្រទេសកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើការវិនិយោគដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ ជាការពិត គម្រោងតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានណែនាំដោយរដ្ឋាភិបាលកម្ពុជា ដើម្បីជំរុញការវិនិយោគដោយមានគោលបំណងបង្កើតនីតិវិធីរដ្ឋបាលឲ្យកាន់តែមានប្រសិទ្ធិភាព និងលើកទឹកចិត្តឲ្យវិស័យឯកជនចូលរួមនៅ គ្រប់ទិដ្ឋភាពទាំងអស់ក្នុងការអភិវឌ្ឍន៍ និងប្រតិបត្តិការក្នុងតំបន់សេដ្ឋកិច្ចពិសេស។ លើសពីនេះទៀត ច្បាប់ និងគោលនយោបាយត្រូវបានដាក់ឲ្យអនុវត្ត ដើម្បីលើកទឹកចិត្ត និងការពារដល់ការវិនិយោគបរទេស ដើម្បីជំរុញកំណើនសេដ្ឋកិច្ចក្នុងស្រុករបស់ប្រទេសកម្ពុជា ជាពិសេស ច្បាប់ស្តីពីការវិនិយោគត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ២០០៣។ ដោយសារប្រទេសកម្ពុជានៅតែបន្តខំយ៉ាងខ្លាំង សម្រាប់ឧស្សាហូបនីយកម្ម កំណើនរឹងមាំត្រូវបានរំពឹងថា នឹងបានមកពីឧស្សាហកម្មសំខាន់ៗនៅក្នុងប្រទេសកម្ពុជា ជាពិសេសពីវិស័យកសិកម្ម រោងចក្រកាត់ដេរ សំណង់ និងទេសចរណ៍។ ការគាំទ្រយ៉ាងសកម្មពីរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ បានជះឥទ្ធិពលទៅដល់ការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសទាំងមូល។ការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសក្នុងប្រទេសកម្ពុជា គឺនៅតែស្ថិតក្នុងដំណាក់កាលដំបូងរបស់ខ្លួននៅឡើយ។ សព្វថ្ងៃនេះ អ្នកផ្តល់ការវិនិយោគផ្ទាល់ពីបរទេសធំៗ មួយចំនួនមកប្រទេសកម្ពុជារួមមាន ប្រទេសចិន កូរ៉េ  ម៉ាឡេស៊ី ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក។ ក្នុងចំណោម ៣៦តំបន់សេដ្ឋកិច្ចពិសេសដែលបានអនុម័ត មានតែ ១៧តំបន់សេដ្ឋកិច្ចពិសេសតែប៉ុណ្ណោះដែលបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ ការអភិវឌ្ឍន៍ដ៏រឹងមាំ និងការរីកចំរើនផ្នែកឧស្សាហកម្ម ត្រូវបានរំពឹងថានឹងធានាបាននូវកំណើនយ៉ាងខ្លាំងសម្រាប់អភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនៅសល់នៅក្នុងប៉ុន្មានឆ្នាំខាងមុខ។ ប្រទេសកម្ពុជាមានបរិយាកាសវិនិយោគគួរឱ្យទាក់ទាញមួយ តាមរយៈបរិយាកាសស្ថិរភាពនយោបាយ គុណប្រយោជន៍ភូមិសាស្ត្រ ប្រព័ន្ធសេដ្ឋកិច្ចបើកចំហ និងថ្លៃកម្លាំងពលកម្មទាប។ លើសពីនេះ រដ្ឋាភិបាលកម្ពុជាបានផ្តល់នូវ រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ពន្ធនាំចូល និងការលើកទឹកចិត្តជាច្រើនដូចជា សេវាកម្មច្រកចេញចូលតែមួយ ក្នុងតំបន់សេដ្ឋកិច្ចពិសេស ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ចូលទៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនោះ។ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង កន្លែងផ្តល់ភាពងាយស្រួលមួយចំនួនក្នុងតំបន់សេដ្ឋកិច្ចពិសេស ជាការទាក់ទាញបន្ថែមអ្នកវិនិយោគិនតំបន់ដើម្បីធ្វើការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ហេតុដូចនេះវាជួយបង្កើនល្បឿននៃការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសផងដែរ។

ផ្អែកតាមការធ្វើបច្ចុប្បន្នភាពថ្មីៗនេះពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត បានទទួលគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ធំៗជាងគេទីពីរ ក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ដែលមានគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចំនួន ៩២ គម្រោង ប៉ុន្តែតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញបានទាក់ទាញដើមទុនវិនិយោគខ្ពស់ជាងគេបំផុតគឺ ៥៦២.៦៨៩.៦៦៦ ដុល្លារអាមេរិក។

## សម្គាល់៖ “ គ.ល.គ” គេម្រោងវិនេិយាគមានលក្ខណៈសម្បត្តិគ្រប់គាន់ )

| ឈ្មោះតំបន់សេដ្ឋកិច្ចពិសេស | ទីតាំង | ឆ្នាំបង្កើត | ផ្ទៃដី ( ហិកតា ) | គ.ល.គ |
|---|---|---|---|---|
| តំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ | ព្រះសីហនុ | ២០០៨ | ១,១១៣ | ១០៩ |
| តំបន់សេដ្ឋកិច្ចពិសេស ភ្នំពេញ | ភ្នំពេញ | ២០០៦ | ៣៥៧ | ៩២ |
| តំបន់សេដ្ឋកិច្ចពិសេស ម៉ាន់ហាផែនស្វាយរៀង | ស្វាយរៀង | ២០០៦ | ១៥៧ | ៣១ |
| តំបន់សេដ្ឋកិច្ចពិសេស តាយ សេង បាវិត | បាវិត | ២០០៧ | ៩៩ | ២៧ |
| តំបន់សេដ្ឋកិច្ចពិសេស សានកូ ប៉ោយប៉ែត | បន្ទាយមានជ័យ | ២០១៣ | ៦៦.៥ | ១០ |
| តំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត អូរនា ង | បន្ទាយមានជ័យ | ២០០៦ | ៤៦៧ | ៥ |
| តំបន់សេដ្ឋកិច្ចពិសេស នាង កុក កោះកុង | កោះកុង | ២០០៧ | ៣៣៥ | ៥ |
| តំបន់សេដ្ឋកិច្ចពិសេស ដ្រេហ្គន ឃីង បាវិត | ស្វាយរៀង | ២០១២ | ១០៦.៥ | ៤ |
| តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ | ក្រុងព្រះសីហនុ | ២០០៩ | ៧០ | ៣ |
| តំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ ១ | ព្រះសីហនុ | ២០០៦ | ១៧៨ | ៣ |
| តំបន់សេដ្ឋកិច្ចពិសេស សានដុង សាន់សែល | ស្វាយរៀង | ២០១៣ | ៩៦ | ២ |
| តំបន់សេដ្ឋកិច្ចពិសេស Goldfame Paksun | កណ្តាល | ២០០៧ | ៨០ | ២ |
| តំបន់សេដ្ឋកិច្ចពិសេស Hi-Park | ស្វាយរៀង | ២០១៣ | ២៦៣.១៣ | ២ |
| តំបន់សេដ្ឋកិច្ចពិសេស H.K.T. | ព្រះសីហនុ | ២០១២ | ៣៤៥ | ១ |
| តំបន់សេដ្ឋកិច្ចពិសេស Kerry Worldbridge | ភ្នំពេញ | ២០១៥ | ៦៣ | ១ |
| តំបន់សេដ្ឋកិច្ចពិសេស Qi Lu (Jian Pu Zhai) | ស្វាយរៀង | ២០១៧ | ១៧៩.១២ | ១ |
| តំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត ភីភី | បន្ទាយមានជ័យ | ២០១៥ | ៦៨.៥ | ១ |
| តំបន់សេដ្ឋកិច្ចពិសេស Suvannaphum | កណ្តាល | ២០១៤ | ២០០ | ១ |

ទស្សនវិស័យទៅថ្ងៃអនាគតសម្រាប់តំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសកម្ពុជា ត្រូវបានព្យាករណ៍ថានឹងនៅមានភាពវិជ្ជមាន ស្របជាមួយនឹងការប្រមើលឃើញនូវកំណើនសេដ្ឋកិច្ចយ៉ាងខ្លាំងក្នុងប្រទេសកម្ពុជា។ ប្រទេសកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើការវិនិយោគដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ ជាការពិត គម្រោងតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានណែនាំដោយរដ្ឋាភិបាលកម្ពុជា ដើម្បីជំរុញការវិនិយោគដោយមានគោលបំណងបង្កើតនីតិវិធីរដ្ឋបាលឲ្យកាន់តែមានប្រសិទ្ធិភាព និងលើកទឹកចិត្តឲ្យវិស័យឯកជនចូលរួមនៅ គ្រប់ទិដ្ឋភាពទាំងអស់ក្នុងការអភិវឌ្ឍន៍ និងប្រតិបត្តិការក្នុងតំបន់សេដ្ឋកិច្ចពិសេស។ លើសពីនេះទៀត ច្បាប់ និងគោលនយោបាយត្រូវបានដាក់ឲ្យអនុវត្ត ដើម្បីលើកទឹកចិត្ត និងការពារដល់ការវិនិយោគបរទេស ដើម្បីជំរុញកំណើនសេដ្ឋកិច្ចក្នុងស្រុករបស់ប្រទេសកម្ពុជា ជាពិសេស ច្បាប់ស្តីពីការវិនិយោគត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ២០០៣។ ដោយសារប្រទេសកម្ពុជានៅតែបន្តខំយ៉ាងខ្លាំង សម្រាប់ឧស្សាហូបនីយកម្ម កំណើនរឹងមាំត្រូវបានរំពឹងថា នឹងបានមកពីឧស្សាហកម្មសំខាន់ៗនៅក្នុងប្រទេសកម្ពុជា ជាពិសេសពីវិស័យកសិកម្ម រោងចក្រកាត់ដេរ សំណង់ និងទេសចរណ៍។ ការគាំទ្រយ៉ាងសកម្មពីរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ បានជះឥទ្ធិពលទៅដល់ការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសទាំងមូល។

ការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសក្នុងប្រទេសកម្ពុជា គឺនៅតែស្ថិតក្នុងដំណាក់កាលដំបូងរបស់ខ្លួននៅឡើយ។ សព្វថ្ងៃនេះ អ្នកផ្តល់កាវិនិយោគផ្ទាល់ពីបរទេសធំៗ មួយចំនួនមកប្រទេសកម្ពុជារួមមាន ប្រទេសចិន កូរ៉េ ម៉ាឡេស៊ី ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក។ ក្នុងចំណោម ៣៦តំបន់សេដ្ឋកិច្ចពិសេសដែលបានអនុម័ត មានតែ ១៧តំបន់សេដ្ឋកិច្ចពិសេសតែប៉ុណ្ណោះដែលបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ ការអភិវឌ្ឍន៍ដ៏រឹងមាំ និងការរីកចំរើនផ្នែកឧស្សាហកម្ម ត្រូវបានរំពឹងថានឹងជានាបាននូវកំណើនយ៉ាងខ្លាំងសម្រាប់អភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនៅសល់នៅក្នុងប៉ុន្មានឆ្នាំខាងមុខ។ ប្រទេសកម្ពុជាមានបរិយាកាសវិនិយោគគួរឱ្យទាក់ទាញមួយ តាមរយៈបរិយាកាសស្ថិរភាពនយោបាយ គុណប្រយោជន៍ភូមិសាស្រ្ត ប្រព័ន្ធសេដ្ឋកិច្ចបើកចំហ និងថ្លៃកម្លាំងពលកម្មទាប។ លើសពីនេះ រដ្ឋាភិបាលកម្ពុជាបានផ្តល់នូវ រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ពន្ធនាំចូល និងការលើកទឹកចិត្តជាច្រើនដូចជាសេវាកម្មច្រកចេញចូលតែមួយ ក្នុងតំបន់សេដ្ឋកិច្ចពិសេស ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ចូលទៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនោះ។ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង កន្លែងផ្តល់ភាពងាយស្រួលមួយចំនួនក្នុងតំបន់សេដ្ឋកិច្ចពិសេស ជាការទាក់ទាញបន្ថែមអ្នកវិនិយោគិនតំបន់ដើម្បីធ្វើការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ហេតុដូចនេះវាជួយបង្កើនល្បឿននៃការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសផងដែរ។

## ១.២.៦. ស្ថានភាពប្រកួតប្រជែង

ចំណុចសំខាន់ផ្សេងៗដំបូងសម្រាប់ការគុណសម្បត្តិនៃការប្រកួតប្រជែងរបស់យើងមានដូចខាងក្រោម៖

## ១.២.៧. ទីតាំងយុទ្ធសាស្ត្រនៃតំបន់សេដ្ឋកិច្ចរបស់យើង

តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ មានទីតាំងស្ថិតនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា និងមានចម្ងាយប្រមាណដប់ប្រាំបី គីឡូម៉ែត្រពីចំណុចកណ្តាលនៃរាជធានីភ្នំពេញ ដែលងាយស្រួលក្នុងការធ្វើដំណើរទៅកាន់កំពង់ផែស្វយ័តភ្នំពេញ ( កំពង់ផែទន្លេអន្តជាតិនៅរាជធានីភ្នំពេញ ) និងមានចម្ងាយប្រាំបី គីឡូម៉ែត្រ ពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ ជាងនេះទៅទៀត តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ ដែលជាផ្លូវគមនាគមន៍ចម្បង និងងាយស្រួលក្នុងការធ្វើដំណើរទៅកាន់កំពង់ផែស្វយ័តក្រុងព្រះសីហនុ។ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ក៏អាចធ្វើដំណើរទៅដល់ដោយមធ្យោបាយគមនាគមន៍ផ្សេងទៀត។ បន្ថែមពីនេះ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ មានទីតាំងស្ថិតនៅជិតផ្លូវដែកសំខាន់របស់កម្ពុជា។ ទីតាំងយុទ្ធសាស្ត្ររបស់ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ បានផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរទៅដល់ និងជួយសម្រួលក្នុងការចែកចាយទំនិញផលិតបានទៅកាន់ តំបន់ផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា។

Poipet PP SEZ ជាតំបន់សេដ្ឋកិច្ចពិសេសថ្មីមួយ ដែលស្ថិតក្រោមការអភិវឌ្ឍ និងប្រតិបត្តិការដោយក្រុមហ៊ុន Poipet PPSEZ Co., Ltd ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Phnom Penh SEZ Plc. វាមានទីតាំងស្ថិតក្នុងខេត្តបន្ទាយមានជ័យ ផ្នែកពាយព្យនៃប្រទេសកម្ពុជា ជាប់នឹងព្រំទល់កម្ពុជា-ថៃ និង មានចម្ងាយ ៨ គីឡូម៉ែត ប៉ែកខាងកើតពីទីក្រុងប៉ោយប៉ែត ដែលតភ្ជាប់ទៅច្រកព្រំដែនសំខាន់មួយជាមួយប្រទេសថៃនៅភាគខាងជើងនៃប្រទេសកម្ពុជា។ ទីតាំងយុទ្ធសាស្ត្រខាងលើមានភាពទាក់ទាញវិនិយោគិន ដែលកំពុងទន្ទឹងរង់ចាំចាប់ផ្តើមផលិតកម្មថ្មី ឃ្លាំង ឬតំបន់ចែកចាយនាពេលអនាគត។ វាមានចម្ងាយ ២៥០ គីឡូម៉ែតពីកំពង់ផែទឹកជ្រៅ Laem Chabang ប្រទេសថៃ និងស្ថិតនៅទីតាំងយុទ្ធសាស្ត្រដោយភ្ជាប់ទៅផ្លូវជាតិលេខ ៥ ( ជាផ្នែកនៃ Asian Highway 1 )។ Poipet PP SEZ ជាចំនុចសំខាន់ភ្ជាប់ទៅទីក្រុងហូជីមិញ- ភ្នំពេញ- សៀមរាប- បាងកក។

## ១.២.៨.ការបង្កើតទំនាក់ទំនងល្អជាមួយនឹងអតិថិជន

បច្ចុប្បន្ន ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ( PPSP ) បានចូលរួមក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសអស់រយៈពេលលើសពីដប់ ( ១០ )ឆ្នាំ។ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ PPSEZ មានវិនិយោគិនតំបន់ចំនួនកៅសិបពីរ ( ៩២ ) (អតិថិជនត្រូវបានស្គាល់ថាជាវិនិយោគិនតំបន់ផងដែរ នៅពេលពួកគេបានបង្កើតប្រតិបត្តិការក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ) ដែលបានបង្កើតរោងចក្ររួចរាល់ ឬកំពុងបង្កើតរោងចក្រផលិតកម្ម/ ដំឡើងម៉ាស៊ីនក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ។ បន្ថែមពីនេះ ថ្ងៃទី៣០ ខែមិថុនាឆ្នាំ២០១៩ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ គឺជាតំបន់សេដ្ឋកិច្ចមួយក្នុងចំណោមតំបន់សេដ្ឋកិច្ចដែលមានដើមទុនវិនិយោគឈានមុខគេក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេស ដែលទទួលបានការអនុញ្ញាតចំនួនសាមសិបប្រាំមួយ ( ៣៦ ) ក្នុងប្រទេសកម្ពុជា។

ជាងនេះទៅទៀត តាមរយៈភាគហ៊ុនិកជនជាតិជប៉ុនរបស់យើង និងបណ្តាញធុរកិច្ចទូលំទូលាយរបស់គណៈគ្រប់គ្រងរបស់ PPSP ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ក្រុមហ៊ុនរបស់យើងបានទាក់ទាញបានយ៉ាងជោគជ័យនូវក្រុមហ៊ុន ជប៉ុនចំនួនសែសិបប្រាំពីរ ( ៤៧ ) ដែលបានមកវិនិយោគក្នុង តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ដែលបានធ្វើឲ្យ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ មានវិនិយោគិនជនជាតិជប៉ុនធំជាងគេ ក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសនានា ក្នុងព្រះរាជាណាចក្រកម្ពុជា។

## ១.២.៩. បុគ្គលិកជាន់ខ្ពស់ ដែលមានបទពិសោធន៍ខ្ពស់

ក្រុមហ៊ុនរបស់យើង ដឹកនាំដោយបុគ្គលិកជាន់ខ្ពស់ដែលមានបទពិសោធន៍ខ្ពស់។ ប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិរបស់យើង លោកជំទាវឧកញ៉ា លីម ឈីវហួរ បានដឹកនាំក្រុមហ៊ុនតាំងពីការបង្កើតក្រុមហ៊ុនដំបូងក្នុងឆ្នាំ២០០៦។ លោកជំទាវឧកញ៉ា លីម ឈីវហួរ បានចូលរួមក្នុងការគ្រប់គ្រង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍអចលនទ្រព្យ និងការវិនិយោគ ការជួញដូរទំនិញប្រើប្រាស់ ការលំហែ និងបដិសណ្ឋារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាអស់រយៈពេលជាងសាមសិប (៣០) ឆ្នាំ។

មួយវិញទៀត នាយកប្រតិបត្តិរបស់យើង លោក Hiroshi Uematsu បានចូលរួមក្នុងរដ្ឋបាលធុរកិច្ច និង វិស័យដែលទាក់ទងនឹងវិស្វកម្មអស់រយៈពេលជាងម្ភៃ (២០) ឆ្នាំ។

ប្រធានក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ បានដឹកនាំបុគ្គលិកជាន់ខ្ពស់ចំនួន ប្រាំបី (០៨) រូប ដែលមានជំនាញផ្សេងៗគ្នាក្នុងការសាងសង់ ការគ្រប់គ្រងគម្រោង វិស្វកម្ម សេវាអតិថិជន ទីផ្សារ គណនេយ្យ ហិរញ្ញវត្ថុ និងផ្នែកគ្រប់គ្រងទំនាក់ទំនងវិនិយោគិន គឺជាចំណែកយ៉ាងធំក្នុងភាពជោគជ័យរបស់សម្ព័ន្ធក្រុមហ៊ុនយើង។

## ១.២.១០. .សេវាកម្មចាំបាច់បន្ថែម

បន្ថែមទៅលើការអភិវឌ្ឍ និងការគ្រប់គ្រង PPSEZ សម្ព័ន្ធក្រុមហ៊ុនរបស់យើងមានសមត្ថភាពក្នុងការផ្តល់សេវាកម្មចាំបាច់បន្ថែមក្នុងតំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ ដែលរួមមាន៖

- សេវាសន្តិសុខដែលផ្តល់ដោយក្រុមហ៊ុន សហ័ស ភីភីអេសអីហ្សិត ជាក្រុមហ៊ុនបុត្រសម្ព័ន្ធ កាន់កាប់ទាំងស្រុងដោយ PPSP។
- ការផ្គត់ផ្គង់ថាមពលអគ្គិសនីបម្រុងដែលមានស្ថេរភាព ពីស្ថានីយ៍ថាមពលអគ្គិសនីឯកជនដែលមានទីតាំងស្ថិតនៅក្នុង PPSEZ ដែលដំណើរការដោយក្រុមហ៊ុន ខូលបេន ភីភីអេសអីហ្សេត ជាក្រុមហ៊ុនជាសម្ព័ន្ធភាពរបស់ PPSP។
- បរិក្ខារផែស្ងួតក្នុង  PPSEZ ដែលប្រតិបត្តិការដោយក្រុមហ៊ុន បុកសេង ភីភីអេសអីហ្សេត ដែលជាក្រុមហ៊ុនជាសម្ព័ន្ធភាពរបស់ PPSP។ និង

ហេដ្ឋារចនាសម្ព័ន្ធដទៃទៀត ដូចជាស្ថានីយ៍ចម្រោះទឹកស្អាត និងស្ថានីយ៍ប្រព្រឹត្តិកម្មទឹកសំអុយឯកជន បណ្តាញទូរគមនាគមន៍ទីធ្លាឃ្លាំងជួល គ្រប់គ្រាន់ សេវាកម្មជួលនិវេសនដ្ឋាន និង  សេវាកម្មដទៃទៀតដែលបំពេញតម្រូវការរបស់អ្នកជួលក្នុង PPSEZ។

## ១.២.១១.ផែនការអនាគត

តទៅមុខទៀត បេសកកម្មរបស់ក្រុមហ៊ុនរបស់យើងគឺ រក្សាតំណែងជាតំបន់សេដ្ឋកិច្ចពិសេសឈានមុខគេក្នុងព្រះរាជាណាចក្រកម្ពុជា។ ផែនការអនាគតរបស់ក្រុមហ៊ុនយើងមានដូចខាងក្រោម៖

## ១.២.១២. ការចាប់ផ្តើមនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារសម្រាប់គម្រោងតំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ប៉ោយប៉ែតថ្មី

ក្នុងឆ្នាំ២០១៤ យើងបានទិញដីទំនេរក្នុងខេត្តបន្ទាយមានជ័យប្រមាណ ៥២,៩៥ ហិកតា ហើយបច្ចុប្បន្នយើងកំពុងសិក្សាលើគម្រោងអភិវឌ្ឍ ដែលអាចធ្វើទៅបានលើដីខាងលើ ដើម្បីប្រែក្លាយវាជាតំបន់សេដ្ឋកិច្ចពិសេស (តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ប៉ោយប៉ែត)។ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ប៉ោយប៉ែត នឹងត្រូវប្រតិបត្តិការដោយក្រុមហ៊ុនបុត្រសម្ព័ន្ធដែលកាន់កាប់ទាំងស្រុងដោយក្រុមហ៊ុនយើង គឺក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអីហ្សិត។

ស្ថិតនៅលើផ្ទៃដី ៦៨,៤ ហិចតា តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ប៉ោយប៉ែត មានទីតាំងស្ថិតនៅប៉ែកខាងកើត និងមានចម្ងាយប្រមាណជា ៥,៦០ គីឡូម៉ែត្រ ពីទីប្រជុំជនក្រុងប៉ោយប៉ែត ដែលតភ្ជាប់ទៅច្រកទ្វារព្រំប្រទល់ស្ថិតនៅទិសខាងជើងឈៀងខាងលិច (ទិសពាយព្យនៃព្រះរាជាណាចក្រកម្ពុជា ជាប់នឹងទល់ដែននៃប្រទេសថៃ។ ទីក្រុងប៉ោយប៉ែតស្ថិតនៅប្រមាណជា ៣០៦ គីឡូម៉ែត្រ ពីទីក្រុងបាងកក និងប្រមាណ ៤១០ គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ។ គិតត្រឹមកាលបរិច្ឆេទ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩នៅក្រុងប៉ោយប៉ែតមានតំបន់សេដ្ឋកិច្ចពិសេសពីរ (០២) ដែលទទួលបានការអនុញ្ញាត មានតំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត អូរនាង និង តំបន់សេដ្ឋកិច្ចពិសេស សានកូ ប៉ោយប៉ែត។

តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ប៉ោយប៉ែត ស្ថិតនៅតំបន់យុទ្ធសាស្ត្រដែលភ្ជាប់ទៅផ្លូវជាតិលេខ៥ ដែលនឹងក្លាយទៅជាផ្នែកមួយនៃផ្លូវហាយវ៉េអាស៊ាន ១ ដែលផ្តល់ភាពងាយស្រួលដល់ការចែកចាយទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា និងផ្នែកខាងក្នុងនៃប្រទេសថៃ និងប្រទេសដទៃទៀតក្នុងតំបន់អាស៊ាន។ គម្រោងនេះ ក៏ស្ថិតនៅប្រមាណជា ២៥០ គីឡូម៉ែត្រ ពីកំពង់ផែ Laem Chabang ដែលជាកំពង់ផែសមុទ្រជ្រៅដ៏សំខាន់មួយស្ថិតនៅផ្នែកខាងកើតនៃប្រទេសថៃ។

ទស្សនៈបឋមសម្រាប់ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ប៉ោយប៉ែត គឺដើម្បីអភិវឌ្ឍគម្រោងនេះឲ្យទៅជា តំបន់សេដ្ឋកិច្ចពិសេសមួយ ដែលអាចទាក់ទាញយកវិនិយោគិនឧស្សាហកម្មធុនស្រាលដែលមានសក្តានុពល ដែលមានបំណងចង់យកព្រះរាជាណាចក្រកម្ពុជាជាទីតាំងផលិតកម្មជំនួសប្រទេសថៃ។ បច្ចុប្បន្ននេះ យើងកំពុងស្ថិតក្នុងដំណាក់កាលរៀបចំឯកសារចាំបាច់នានា ដើម្បីដាក់ស្នើសុំការអនុញ្ញាតពីអាជ្ញាធរពាក់ព័ន្ធ ដើម្បីឲ្យ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ប៉ោយប៉ែត នេះក្លាយជាតំបន់សេដ្ឋកិច្ចពិសេស។

ក្នុងកាលៈទេសៈនេះ យើងគ្រោងអភិវឌ្ឍ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ប៉ោយប៉ែត ជាពីរ ( ០២ ) ដំណាក់កាល៖ ដំណាក់កាល១ និងដំណាក់កាល២។ ផែនទីនៃគម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ប៉ោយប៉ែត បានដាក់បង្ហាញដូចខាងក្រោម៖




ដំណាក់កាល១ នៃ ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត បានចាប់ផ្ដើមសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារចម្បងនៅដំណាច់ឆ្នាំ២០១៦ គ្របដណ្ដប់លើផ្ទៃដីប្រមាណ ៣៤,៨៣ ហិកតាដែលមានចំនួនប្រមាណ ២១.៤០ ហិកតាត្រូវបានបម្រុងទុកសម្រាប់ផ្ទុករោងចក្រសរុបចំនួន ៤០ ( ៤០ ) ដែលមានទំហំចាប់ពីប្រមាណ ០.៤០ ហិកតាដល់ ០.៩០ ហិកតា។ វាក៏នឹងមានតំបន់ពាណិជ្ជកម្មកំពង់ផែស្ងួតកន្លែងស្នាក់នៅរបស់កម្មករអគារការិយាល័យរដ្ឋបាលនិងកន្លែងផ្សេងទៀតនិងអគារហេដ្ឋារចនាសម្ព័ន្ធ។ គម្រោងនេះត្រូវការចំនួនទឹកប្រាក់ប្រមាណ ៨.២៣ លានដុល្លារអាមេរិកទៅលើហេដ្ឋារចនាសម្ព័ន្ធនិងការអភិវឌ្ឍដូចជាការអភិវឌ្ឍដី បណ្ដាញផ្លូវថ្នល់ ទឹក និងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី លូ ប្រព័ន្ធបង្ហូរទឹក របងហ៊ុមព័ទ្ធ និងបរិក្ខាផ្សេងៗទៀត។

នៅពេលខាងមុខ ដំណាក់កាល២ នៃ ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត នឹងចាប់ផ្ដើមសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារចម្បង។  ការសាងសង់នេះនឹងត្រូវគ្របដណ្ដប់លើផ្ទៃដីប្រមាណជា ២០,៦៧ ហិកតា ដែលផ្ទៃដីប្រមាណជា ១៥,៨៩ ហិកតា នឹងត្រូវបែងចែកសម្រាប់ទីតាំងរោងចក្រសរុបចំនួនម្ភៃប្រាំបី ( ២៨ ) ដែលទីតាំងរោងចក្រនីមួយៗមានទំហំចាប់ពី ០,៣៨ ហិកតា ដល់ ០,៨០ ហិកតា ហើយផ្ទៃដីដែលនៅសល់គឺត្រូវបានរៀបចំធ្វើជាតំបន់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម។

បន្ទាប់ពីបានប្រមូលទិញដីបន្ថែមក្នុងកំឡុងពេល ២ ឆ្នាំចុងក្រោយនេះ ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត មានផ្ទៃដីសរុប ៦៨.៤ ហិកតា។

## ១.២.១៣.ការពង្រីកសេវាកម្មពាក់ព័ន្ធផ្សេងៗ

ទោះបីជាលំហូរនៃប្រាក់ចំណូលរបស់យើងបច្ចុប្បន្នភាគច្រើនទទួលបានពីការលក់ដី និងការជួល តែយើងព្យាយាមបង្កើតគំរូអាជីវកម្មប្រកបដោយនិរន្តរភាពសម្រាប់ការអភិវឌ្ឍតំបន់ឧស្សាហកម្ម។ យើងបានខិតខំប្រឹងប្រែងធ្វើការណែនាំ និងបង្កើនប្រាក់ចំណូលពីប្រភពដែលប្រកបដោយនិរន្តរភាពអោយបានកាន់តែច្រើន។
បច្ចុប្បន្ននេះ ក្នុងបរិវេណ PPSEZ យើងបានដំឡើងប្រព័ន្ធផ្គត់ផ្គង់ទឹកឯកជនមួយ ដែលរួមមានអាងស្តុកទឹក និងប្រព័ន្ធប្រព្រឹត្តិកម្មទឹក ដែលមានសមត្ថភាពផ្គត់ផ្គង់ទឹកប្រមាណជា ១.៩០០ម៣ ក្នុងមួយថ្ងៃ ដែលបង្កើននូវការផ្គត់ផ្គង់តាមតម្រូវការនៃកំណើនវិនិយោគិនមកពីគ្រប់ទិសទីដូចដែលបានរំពឹងទុក។ ប្រព័ន្ធនេះ នឹងកាត់បន្ថយនូវការកាត់ផ្តាច់ការផ្គត់ផ្គង់ទឹក ដែលអាចកើតមាននៅក្នុង PPSEZ និងធានាជូនវិនិយោគិនក្នុង PPSEZ ជាពិសេសអ្នកដែលប្រតិបត្តិពាក់ព័ន្ធនឹងឧស្សាហកម្មអាហារ និងភេសជ្ជៈ ដែលត្រូវការការផ្គត់ផ្គង់ទឹកឲ្យបានឋិតថេរសម្រាប់ប្រតិបត្តិការរបស់ខ្លួន មិនឲ្យប្រឈមនឹងការកាត់ផ្តាច់ទឹកឡើយ។ គិតត្រឹមកាលបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ការប្រើប្រាស់ទឹកពីប្រព័ន្ធផ្គត់ផ្គង់ទឹកឯកជនរបស់យើងមានប្រមាណជា ៥.៣០០ម៣ ក្នុងមួយថ្ងៃ ដែលស្មើនឹងការប្រើប្រាស់៣៦% ។ ការប្រើប្រាស់ទឹកនៅតែបន្តកើនឡើងតាំងពីឆ្នាំមុនដោយសារប្រតិបត្តិការថ្មីពីក្រុមហ៊ុនភេសជ្ជៈក្នុងតំបន់។
ដូចដែលបានរៀបរាប់ខាងលើ យើងបានការបង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធថ្មីដោយជោគជ័យដែលផ្តល់ជូននូវសេវាពាណិជ្ជកម្មសំណង់នៅក្នុងគោលបំណងទាក់ទាញនូវកំណើនតម្រូវការពីអតិថិជនរបស់យើង។ ក្រុមជំនាញរបស់យើង ទទួលខុសត្រូវសម្រាប់ការផ្តល់នូវសេវាដ៏ល្អ និងការងារផ្នែកសំណង់ទាំងនេះដល់អតិថិជនរបស់យើង។

## ១.៣. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសទី១ របស់បុគ្គលចុះបញ្ជីលក់មូលបត្រ

នាព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ អ្នកឧកញ៉ា គិត ម៉េង ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុនភ្នំពេញ PPSP បានអញ្ជើញគណៈប្រតិភូមួយក្រុមដែលរួមមាន សមាជិកសភាពាណិជ្ជកម្មកម្ពុជា ដៃគូអាជីវកម្មសក្តានុពល និងអ្នកផ្តល់សេវាកម្ម មកទស្សនាតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ( PPSEZ )។ គោលបំណងសំខាន់មួយនៃដំណើរទស្សនកិច្ចនេះគឺដើម្បីបង្ហាញអ្នកទាំងអស់គ្នាពីរបៀបដែលតំបន់នេះកំពុងដំណើរការ និងបង្ហាញពីការអភិវឌ្ឍន៍ និងសមិទ្ធិផលនាពេលបច្ចុប្បន្ន ក៏ដូចជាបង្កើតឱកាសដើម្បីស្គាល់គ្នាសម្រាប់កិច្ចសហការដែលអាចធ្វើទៅបាននាពេលអនាគតរវាងអ្នកអភិវឌ្ឍន៍តំបន់ និងអ្នកពាក់ព័ន្ធផ្សេងទៀត។
